# សុន្ទរកថារបស់ លោក ជីចា តាយហ្សុ
## លេខាទីពីរ ស្ថានទូតជប៉ុន
## ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ប្រព័ន្ធលូ និងផ្លូវ ក្នុងឃុំសង្កែពីរ ខេត្តព្រះវិហារ
## ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**
- **សូមគោរព ឯកឧត្តម ឡុង សុវណ្ណ ប្រធានក្រុមប្រឹក្សាខេត្តព្រះវិហារ**
- **សូមគោរព លោក សំ លាងទ្រី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ**
- **សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងណាស់ ដែលបានមកចូលរួមក្នុងពិធីសម្ពោធប្រព័ន្ធលូ និងផ្លូវក្នុងឃុំសង្កែពីរ ខេត្តព្រះវិហារ ជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឡុង សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្តព្រះវិហារ។ ជាបឋម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ និងប្រជាជនដែលរស់នៅក្នុងតំបន់នេះ ដែលបានរៀបចំឲ្យមានកម្មវិធីនេះឡើង។

ការការពារទឹកជំនន់គឺជាវិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុនសម្រាប់កម្ពុជា ហើយជាក់ស្តែងគម្រោងកែលម្អប្រព័ន្ធលូជាច្រើន ត្រូវបានអនុវត្តទាំងនៅទីក្រុង និងតំបន់ជនបទ។ ហើយឥឡូវនេះគម្រោងតំឡើងលូប្រអប់ពីរ និងការកែលម្អផ្លូវគ្រួសក្រហមប្រវែង៤,០០០ម៉ែត្រនៅក្នុងឃុំសង្កែពីរត្រូវបានអនុវត្តនៅក្នុងខេត្តព្រះវិហារ។

ខ្ញុំបានទទួលដំណឹងថា ការសាងសង់ប្រព័ន្ធលូ និងកែលម្អផ្លូវនៅក្នុងឃុំសង្កែពីរនេះ អាចផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ១,៥០០នាក់រស់នៅក្នុងភូមិចំនួន៣ ដោយផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់មន្ទីរពេទ្យខេត្ត វិទ្យាល័យ និងសាលាបឋមសិក្សាជាដើម។ គម្រោងនេះត្រូវបានរំពឹងថានឹងរួមចំណែកក្នុងការលើកស្ទួយសេដ្ឋកិច្ចក្នុងតំបន់ផងដែរ។

ខ្ញុំសង្ឃឹមថាមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ នឹងថែទាំប្រព័ន្ធលូ និងផ្លូវនេះឲ្យបានល្អ ដើម្បីអោយប្រជាពលរដ្ឋក្នុងតំបន់នេះ អាចទទួលបានអត្ថប្រយោជន៍យូរអង្វែង។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាប្រព័ន្ធលូ និងផ្លូវនេះ នឹងក្លាយជា

និមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ ព្រមទាំងជួយពង្រឹងជាបន្តនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**